# សុន្ទរកថា

## ឯកឧត្តម ប៉ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ
## និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
## តំណាងដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
## ថ្លែងក្នុងឱកាសសម្ពោធដាក់ឱ្យប្រើប្រាស់សាលថ្មីសម្រាប់ទទួលអ្នកដំណើរមកដល់ និង សាលថ្មីសម្រាប់រង់ចាំចេញដំណើរ នៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ

អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧

- សូមក្រាបថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ
- ឯកឧត្តម លោកជំទាវ ឯកអគ្គរដ្ឋទូត ឯកអគ្គរាជទូត ជាទីគោរពរាប់អាន
- ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់
- លោក នីកូឡា ណូតបា អគ្គនាយកក្រុមហ៊ុនសម្បទាន វ៉ាំស៊ី អែផត និងជាប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន ខេមបូឌា អែផត
- ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី នាងកញ្ញា ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ជាទីមេត្រី!

ក្នុងនាម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំមានកិត្តិយស និងសេចក្តីរីករាយជាអនេកកប្បការ ដោយបានមកចូលរួមជាអធិបតីក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នូវសាលថ្មីសម្រាប់ទទួលអ្នកដំណើរមកដល់ និងសាលថ្មីសម្រាប់ភ្ញៀវរង់ចាំចេញដំណើរ នៅអាកាសយាន្តដ្ឋានអន្តរជាតិភ្នំពេញនាពេលនេះ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះវត្តមានរបស់ឯកឧត្តម លោកជំទាវ ភ្ញៀវជាតិ និងអន្តរជាតិ។

ក្នុងនាមរាជរដ្ឋាភិបាល និងក្នុងនាមខ្ញុំព្រះករុណាខ្ញុំផ្ទាល់មានសេចក្តីរីករាយយ៉ាងក្រៃលែងដោយបានឃើញនូវសមិទ្ធផល និងការរីកចម្រើននានាក្នុងអាកាសយាន្តដ្ឋានអន្តរជាតិភ្នំពេញ ដែលសមិទ្ធផលទាំងអស់នេះគឺជាការរួមវិភាគទានមួយដ៏សំខាន់របស់ក្រុមហ៊ុន Cambodia Airports ក្នុងការរក្សាកំណើនសេដ្ឋកិច្ចឲ្យមានតុល្យភាព ដើម្បីជំរុញការវិវឌ្ឍន៍ឈានទៀងរបស់ប្រទេសជាតិ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំព្រះករុណាខ្ញុំសូមកោតសរសើរចំពោះការខិតខំប្រឹងប្រែងរបស់ក្រុមហ៊ុន Cambodia Airports ដែលបានរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការកសាងនូវសមិទ្ធផលនានា ជាពិសេសការរៀបចំនូវហេដ្ឋារចនាសម្ព័ន្ធ នៃអាកាសយាន្តដ្ឋានអន្តរជាតិភ្នំពេញដែលយើងទាំងអស់គ្នាកំពុងប្រារព្ធពិធីសម្ពោធយ៉ាងឱឡារិកដាក់ឲ្យប្រើប្រាស់ជាផ្លូវការ ដើម្បីបង្កលក្ខណៈងាយស្រួលបន្ថែមទៀតដល់ភ្ញៀវជាតិ និងអន្តរជាតិ។

ជាមួយគ្នានេះ ខ្ញុំសូមថ្លែងអំណរគុណផងដែរចំពោះដៃគូសហប្រតិបត្តិការសំខាន់ៗនានា រួមទាំងវិស័យឯកជន ពិសេសក្រោមកិច្ចសហប្រតិតបត្តិការបារាំង ដែលបានសហកាពុះពារធ្វើការរួមគ្នានារយៈពេលកន្លងមកនេះ ក្នុងបុព្វហេតុឲ្យការរៀបចំអាកាសយានដ្ឋានអន្តរជាតិភ្នំពេញដំណើរការប្រកបដោយភាពល្អប្រសើរ។

នៅមុននេះបន្តិចលោក **នីកូឡា ណូតបា** អគ្គនាយកក្រុមហ៊ុនសម្បទាន **វីអាយអិនស៊ីអាយ អែផត** និងជាប្រធានក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន Cambodia Airports អាកាសយានដ្ឋានអន្តរជាតិភ្នំពេញបានធ្វើសេចក្តីរាយការណ៍ជូនយ៉ាងល្អិតល្អន់រួចមកហើយអំពីលទ្ធផលនានា ស្តីពីដំណើការនៃការសាងសង់សាលថ្មីសម្រាប់ទទួលអ្នកដំណើរមកដល់ និងសាលថ្មីសម្រាប់ភ្ញៀវរង់ចាំចេញដំណើរ ព្រមទាំងការជួសជុលសំណង់អគារនានា ក៏ដូចជាចក្ខុវិស័យក្នុងការគិតគូរយ៉ាងល្អិតល្អន់ទៅថ្ងៃមុខ ឆ្លើយតបទៅនឹងចំនួនភ្ញៀវទេសចរណ៍ដែលកើនឡើងជាបន្តបន្ទាប់ក្នុងអាកាសយានដ្ឋានអន្តរជាតិភ្នំពេញយើងនេះ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំព្រះករុណាខ្ញុំសូមរំឭកឡើងវិញអំពីការចាប់ផ្តើមឡើង នៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ គឺបានកសាងឡើងនៅដើមទសវត្សរ៍ឆ្នាំ៦០ ដែលនេះគឺបានឆ្លុះបញ្ចាំងអំពីគុណប្រយោជន៍ និងសារៈសំខាន់ក្នុងការបើកចំហឱ្យកម្ពុជាមានការហោះហើ ក្រោមកិច្ចសហប្រតិបត្តិការបារាំង (**កម្ពុជា-បារាំង**)។ តាមរយៈវត្តមានរបស់ខ្ញុំនៅក្នុងឱកាសនេះ ខ្ញុំពិតជាមានសេចក្តីរីករាយយ៉ាងក្រៃលែង ដែលក្នុងនាមខ្ញុំជាតំណាងដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា តំណាងឱ្យរាជរដ្ឋាភិបាល តែងតែគាំទ្រនូវទំនាក់ទំនងរវាងប្រទេសទាំងពីរ (**កម្ពុជា-បារាំង**) ដែលមានប្រវត្តិជាង៥ទសវត្សរ៍កន្លងមកហើយ។ ខ្ញុំនៅចាំបានថា រយៈពេល២២ឆ្នាំកន្លងទៅ ភាពជាដៃគូប្រកបដោយផ្លែផ្កាបំផុតមួយរវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុន Cambodia Airports បានចាប់កំណើតឡើង គឺភាពជាដៃគូដែលបានប្រែក្លាយទៅជាកត្តាកំណត់ដ៏សំខាន់មួយសម្រាប់ការអភិវឌ្ឍព្រះរាជាណាចក្រកម្ពុជា និងការរីចម្រើននៃឧស្សាហកម្មទេសចរណ៍របស់ខ្លួនសម្រាប់ការបើកចំហកម្ពុជាទៅកាន់ពិភពលោក និងពិភពលោកមកកាន់កម្ពុជា ដែលបានចាប់ផ្តើមឡើងនៅឆ្នាំ១៩៩៥ គឺនៅអាកាសយានដ្ឋានភ្នំពេញអន្តរជាតិនេះតែម្តង។ បន្ទាប់ពីបានរៀបចំកសាងហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មនានានៅអាកាសយានដ្ឋាន អន្តរជាតិភ្នំពេញរហូតឈានដល់កម្រិតស្តង់ដាអន្តរជាតិ រាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុន Cambodia Airports បានអនុវត្តរួមគ្នានូវយុទ្ធសាស្ត្រឈ្នះៗ ក្នុងការអភិវឌ្ឍខ្សែបណ្តាញអាកាសយានដ្ឋានអន្តរជាតិជាបន្តបន្ទាប់ ដែលដំបូងឡើយបានបន្ថែមអាកាសយានដ្ឋានអន្តរជាតិសៀមរាបនៅឆ្នាំ២០០១ ហើយបន្ទាប់មកទៀតគឺអាកាសយានដ្ឋានក្រុងព្រះសីហនុនៅឆ្នាំ២០០៦ ដែលក្នុងរយៈពេលនោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយរដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់កិត្តិយសធ្វើជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងការសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវស្ថានីយ៍អ្នកដំណើរអន្តរជាតិមកដល់នៅអាកាសយានដ្ឋានអន្តរជាតិសៀមរាប និងនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។ កិច្ចការដែលរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុន Cambodia Airports ក៏ដូចជាដៃគូទាំងអស់ក្នុងវិស័យទេសចរណ៍បានសហការរួមគ្នាធ្វើការអភិវឌ្ឍនជាបន្តបន្ទាប់កន្លងមក គឺពិតជាបានឆ្លើយតបទៅនឹងកំណើនភ្ញៀវទេសចរណ៍ដែលបានកើនឡើងជាបន្តបន្ទាប់។

- **ឯកឧត្តម លោកជំទាវ ឯកអគ្គរដ្ឋទូត ឯកអគ្គរាជទូត**
- **ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី**

ជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធថ្មីៗទាំងនេះ បានសបញ្ជាក់ឲ្យឃើញថា៖ គឺជាការវិនិយោគដ៏ច្រើន និងមានប្រយោជន៍យ៉ាងខ្លាំងសម្រាប់ព្រះរាជាណាចក្រកម្ពុជា ជាអាទិ៍គឺការបង្កើតការងារក្នុងស្រុករបស់យើង។ អាកាសយានដ្ឋាននៅក្នុងរាជធានីភ្នំពេញ រួមទាំងអាកាសយានដ្ឋាននៅខេត្តសៀមរាប និងខេត្តព្រះសីហនុគឺមានសមត្ថភាពពេញលេញក្នុងការទទួលអ្នកដំណើរបានរហូតដល់៧លាននាក់ ដែលនឹងមកទស្សនានៅប្រទេសកម្ពុជា ហើយតួលេខនេះក្រសួងទេសចរណ៍បានប៉ាន់ប្រមាណថា៖ ចំនួនភ្ញៀវទេសចរណ៍អាចនឹងកើនឡើងរហូតដល់៧លាននាក់នៅឆ្នាំ២០២០។ ជាការពិត វិស័យអាកាសចរណ៍ ដែលគ្របដណ្តប់លើការដឹកជញ្ជូនអ្នកដំណើរ និងទំនិញ គឺមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងពិភពលោកបែបសាកលភាវូបនីយកម្ម ដែលវិស័យនេះបានរួមចំណែកសម្រួលដល់ការធ្វើដំណើររបស់មនុស្ស ការងារដឹកជញ្ជូនទំនិញនានា ការចែករំលែកនូវវប្បធម៌របស់ប្រទេសនីមួយៗ ការទំនាក់ទំនងខាងផ្នែកវិនិយោគ សេដ្ឋកិច្ច ពាណិជ្ជកម្ម និងសេវាកម្មនានា ដែលក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញមានការកើនឡើងនូវភ្ញៀវទេសចរណ៍យ៉ាងច្រើនគួរឱ្យកត់សម្គាល់។

តាមរយៈការវិនិយោគរបស់ក្រុមហ៊ុន Cambodia Airports លើវិស័យអាកាសចរ រាជរដ្ឋាភិបាលកម្ពុជាជាមួយនឹងក្រុមហ៊ុន Cambodia Airports នៅតែបន្តខិតខំប្រឹងប្រែង ព្រមទាំងយកចិត្តទុកដាក់ខ្ពស់ទៅលើកិច្ចការទាំងឡាយក្នុងវិស័យនេះ ដោយធានាឲ្យបាននូវលទ្ធផលផ្តែផ្កាលើការកសាងនូវសមិទ្ធផលថ្មីៗបន្ថែមទៀតទៅថ្ងៃមុខ ដើម្បីបានជាឧត្តមប្រយោជន៍មួយក្នុងការរួមចំណែកជួយជំរុញទិសដៅរបស់រាជរដ្ឋាភិបាលឲ្យទទួលបាននូវជោគជ័យ និងភាពរុងរឿងថ្មីៗថែមបន្ថែមទៀតជូនដល់ព្រះរាជាណាចក្រកម្ពុជា។ ការចូលរួមវិនិយោគរបស់ក្រុមហ៊ុន Cambodia Airports ក៏ដូចជាដៃគូវិនិយោគដ៏ទៃទៀត គឺជាឧបករណ៍ឈ្នះៗមួយដែលសបញ្ជាក់ឲ្យឃើញពីភាពរីចម្រើន និងជឿនលឿនផ្នែកសង្គម ដោយហេតុថា កាវិនិយោគទាំងនេះបាននឹងកំពុងផ្តល់នូវក្របខណ្ឌការងារប្រកបដោយភាពទាក់ទាញ ជូនដល់បុគ្គលិក ក៏ដូចជាក្រុមគ្រួសាររបស់ប្រជាពលរដ្ឋកម្ពុជាផងដែរ។ ជាក់ស្តែងការសហការរវាងរាជរដ្ឋាភិបាលកម្ពុជាជាមួយនឹងក្រុមហ៊ុន Cambodia Airports ក្រុមហ៊ុនក៏បានផ្តល់នូវការធានារ៉ាប់រងផ្នែកសុខភាព បង្កើតនូវកម្មវិធីសំចៃប្រាក់ខែ ហើយនាពេលថ្មីៗនេះទៀតក្រុមហ៊ុនក៏បានទិញនូវកញ្ចប់ធានារ៉ាប់រងអាយុជីវិតជូនដល់បុគ្គលិករបស់ខ្លួនទាំងអស់ថែមទៀតផង។ ជាមួយនេះក្រោមការសហការរបស់រាជរដ្ឋាភិបាល ក្រុមហ៊ុនក៏បានអនុវត្តការងារច្នៃប្រឌិតថ្មីៗបន្ថែមទៀតលើវិស័យបរិស្ថានដោយមានការផ្តួចផ្តើមគំនិតក្នុងការអនុវត្តគោលនយោបាយកាត់បន្ថយការបញ្ចេញឧស្ម័នជាតិពុល កាបោន និងការបង្កើតឡើងនូវស្ថានីយ៍ចម្រោះទឹកកខ្វក់នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងនៅអាកាសយានដ្ឋានអន្តរជាតិសៀមរាប ដើម្បីរក្សាបាននូវសុខភាពអនាម័យល្អ ក្នុងការលើកម្ពស់សុខមាលភាពរបស់ប្រជាពលរដ្ឋភ្ញៀវជាតិ និងអន្តរជាតិ។

- **ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី**

ទស្សនៈវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាលកម្ពុជា បានផ្សារភ្ជាប់ជាមួយនឹងគោលដៅអភិវឌ្ឍសហស្សវត្សរ៍ ដោយក្នុងនោះការលើកស្ទួយវិស័យអាកាសចរ ក៏ជាផ្នែកមួយដ៏មានសារៈសំខាន់ក្នុងការបង្កើតនូវកាលានុវត្តភាព ធ្វើឲ្យកម្ពុជាអាចឈានឆ្ពោះទៅរកវឌ្ឍនភាពជឿនលឿនរុងរឿងក្នុងរយៈពេលមួយដ៏ខ្លីខាងមុខ ហើយយើងជឿជាក់ថា យើងនឹងជំនះបាននូវរាល់បញ្ហា និងធានាឱ្យបាននូវកំណើនភ្ញៀវទេសចរណ៍ដែលបានធ្វើការហោះហើរមកកាន់ព្រះរាជាណាចក្រកម្ពុជា។ សមិទ្ធផលដែលកើតចេញពីការអភិវឌ្ឍក្នុងវិស័យអាកាសចរ

ព្រលានយន្តហោះអន្តរជាតិចំនួនបីរបស់យើង ពិតជាបានរួមចំណែកដល់ភាពរុងរឿងជូនព្រះរាជាណាចក្រកម្ពុជា ដោយបានអនុញ្ញាតឲ្យភ្ញៀវទេសចរណ៍រាប់លាននាក់ក្នុងមួយឆ្នាំៗ ធ្វើការហោះហើរមកទស្សនាប្រទេសកម្ពុជា បានមើលឃើញនូវការរីកចម្រើន និងវប្បធម៌ដ៏ប្រពៃរបស់យើងថែមទៀតផង។ នៅថ្ងៃខាងមុខនេះ ជើងហោះហើរថ្មីៗនឹងត្រូវបានបើកបន្តបន្ទាប់ជារៀងរាល់ឆ្នាំ ហើយគោលដៅហោះហើរដ៏ពេញនិយមជាងគេនឹងកាន់តែខិតជិតកៀកបង្កើយ ដែលក្នុងឆ្នាំកន្លងទៅ និងប៉ុន្មានខែចុងក្រោយមកនេះ យើងឃើញមានក្រុមហ៊ុនអាកាសចរណ៍ធំៗលំដាប់ពិភពលោកជាច្រើនបានហោះហើរមកកាន់រាជធានីភ្នំពេញ និងខេត្តសៀមរាប។

- **ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ**

ក្នុងនាម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយរដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមសម្តែងនូវការកោតសរសើរខ្ពស់ជូនដល់ក្រុមការងាររបស់ក្រុមហ៊ុន Cambodia Airports និងដៃគូទាំងអស់របស់ក្រុមហ៊ុន រួមមានក្រុមហ៊ុនគម្រោងសំណង់ធំៗ **វីអាយអិនស៊ីអាយ** និងក្រុមហ៊ុន **មូហ៊ីបបា** ដែលសម្រេចបានយ៉ាងជោគជ័យនូវកិច្ចការទាំងឡាយក្នុងពេលតែមួយ ពោលគឺការងារសាងសង់អគារថ្មី និងការងារជួសជុល ហើយទន្ទឹមនឹងការងារសាងសង់ និងជួសជុលនេះ អាកាសយាន្តដ្ឋានអន្តរជាតិភ្នំពេញក៏នៅតែបន្តផ្តល់សេវាកម្មល្អជូនដល់អ្នកដំណើរដោយគ្មានភាពរអាក់រអួលទាំងភ្ញៀវជាតិ និងអន្តរជាតិ។

ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរចំពោះថ្នាក់ដឹកនាំ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល និងមន្ត្រីគ្រប់លំដាប់ថ្នាក់ ដែលបានសហការ សម្របសម្រួល ក្នុងការអនុវត្តការងារបានល្អប្រសើរនារយៈពេលកន្លងមក និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់គណៈកម្មាធិការអាកាសយានដ្ឋានរួមមាន ផ្នែកអន្តោប្រវេសន៍ ស្ថាប័នគយ នគបាល និងបុគ្គលិកអាកាសយាន្តដ្ឋានទាំងអស់ ដែលបានសហការរួមសាមគ្គីគ្នាក្នុងការអនុវត្តការងារប្រកបដោយជោគជ័យ។

ជាទីបញ្ចប់ ខ្ញុំព្រះករុណាខ្ញុំសូមប្រសិទ្ធពរដ៏ប្រសើរប្រគេនដល់ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងជូនពរដល់ ឯកឧត្តម លោកជំទាវ អ្នកឧញ៉ា លោកឧញ៉ា លោក លោកស្រី ព្រមទាំងជនរួមជាតិទាំងអស់ សូមសមប្រកបតែនឹងពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ កុំបីឃ្លៀងឃ្លាតឡើយ។

ឆ្លៀតក្នុងឱកាសដ៏ប្រពៃនេះ ខ្ញុំព្រះករុណាខ្ញុំសូមប្រកាស សម្ពោធដាក់ឱ្យប្រើប្រាស់សាលថ្មីសម្រាប់ទទួលអ្នកដំណើរមកដល់ និងសាលថ្មីសម្រាប់ភ្ញៀវរង់ចាំចេញដំណើរ នៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ចាប់ពីពេលនេះតទៅ។

**សូមអរគុណ**!